**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម** **ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** **ក្រសួងរ៉ែ និងថាមពល**

**លេខ:** ០០៤៦៣ ពណ.អវង.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ លើលិខិតលេខ ៥០១១សហវ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិមានការប្រែប្រួលខុសប្រក្រតី

# សម្រេច

**ប្រការ១ ._**

ត្រូវបានកំណត់រូបមន្ត សម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ដើម្បីឱ្យថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយប្រេងឥន្ធនៈឡើងចុះតាមតម្លៃប្រេងនៅលើទីផ្សារអន្តរជាតិ។ ការកំណត់រូបមន្តនេះសម្រាប់ដាក់ឱ្យអនុវត្តតែទៅលើការលក់រាយប្រេងឥន្ធនៈប៉ុណ្ណោះ។

**ប្រការ២ ._**

រូបមន្តថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមបណ្តាស្ថានីយប្រេងឥន្ធនៈនៅកម្ពុជាត្រូវបានកំណត់ ដូចខាងក្រោម៖

តម្លៃរាយ /លីត្រ = មធ្យមភាគ MOPS + ពន្ធ + PREMIUM + អាករលើតម្លៃបន្ថែម (VAT OUT)

- **MOPS** (Mean of Platts Singapore) សំដៅលើតម្លៃមធ្យមភាគនៃផលិតផលប្រេងឥន្ធនៈលក់ដុំនៅប្រទេសសិង្ហបុរី ដែលចេញផ្សាយដោយក្រុមហ៊ុន Platts
- **PREMIUM** : សំដៅលើ ចំណាយទូទៅ + ពន្ធលើប្រាក់ចំណេញ + ប្រាក់ចំណេញ
- **ពន្ធ** : សំដៅលើ ពន្ធគយ + អាករបន្ថែម + អាករពិសេស
- ឧទាហរណ៍: ថ្លៃលក់រាយប្រេងសាំងសម្រាប់ប្រើប្រាស់ចាប់ពីថ្ងៃទី១២ ដល់ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ តាមរូបមន្តខាងលើត្រូវគណនាដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- មធ្យមភាគ MOPS ចាប់ពីថ្ងៃទី០១-១១ ខែមិថុនា ឆ្នាំ២០១៨ 0,៥២៥៨ដុល្លារ | | |
| ២- ពន្ធ៖ | | 0,១៧៩១ដុល្លារ |
| ពន្ធគយ | 0, 0៧២៦ ដុល្លារ | |
| អាករបន្ថែម | 0, 0២00 ដុល្លារ | |
| អាករពិសេស | 0, 0៨៦៥ ដុល្លារ | |
| ៣- PREMIUM | | 0,២000ដុល្លារ |
| ៤- អាករលើតម្លៃបន្ថែម ១០ % នៃ (១ + ២ + ៣) | | 0,0៩0៥ដុល្លារ |
| ថ្លៃលក់រាយ /លីត្រ (១ + ២ + ៣ + ៤ ) | | 0,៩៩៥៤ដុល្លារ |
| ជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ ៤ 0៦0 រៀល /ដុល្លារ | | **៤ 0៥0រៀល។** |

**ប្រការ៣ ._**

តម្លៃ Premium ត្រូវបានកំណត់ 0,២0ដុល្លារ ក្នុងមួយលីត្រ សម្រាប់ប្រេងសាំងធម្មតា (EA92)។ ចំណែកតម្លៃ Premium សម្រាប់ប្រេងម៉ាស៊ូតត្រូវបានកំណត់ 0,២៣ដុល្លារ ក្នុងមួយលីត្រ (តម្លៃគិតជាដុល្លារអាមេរិក រួចគិតជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ចេញដោយធនាគារជាតិនៃកម្ពុជា)។ តម្លៃ Premium សម្រាប់ប្រេងសាំងស៊ុបពែមិនត្រូវបានកំណត់ទេ។ ស្ថានីយលក់រាយប្រេងឥន្ធនៈនៅកម្ពុជា អាចលក់ប្រកួតប្រជែងក្នុងតម្លៃមួយទាបជាងថ្លៃដែលបានគណនាដោយរូបមន្តខាងលើ។

**ប្រការ៤ ._**

នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នៃក្រសួងពាណិជ្ជកម្ម ត្រូវគណនាថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាតាមរូបមន្តខាងលើ និងចេញថ្លៃលក់រាយជូនក្រុមហ៊ុនប្រេងឥន្ធនៈនៅរៀងរាល់ថ្ងៃទី០១ ថ្ងៃទី១១ និងថ្ងៃទី២១ នៃខែនីមួយៗ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអាចចេញសេចក្តីជូនដំណឹងភ្លាមៗ ដោយកំណត់ឱ្យចេញថ្លៃលក់រាយជូនក្រុមហ៊ុនប្រេងឥន្ធនៈនៅក្នុងរយៈពេល ១០ថ្ងៃម្តង ឬ ១៥ថ្ងៃម្តង តាមការចាំបាច់ ដើម្បីឱ្យមានសមាមាត្រត្វារវាងតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ និងតម្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា សម្រាប់រក្សាស្ថិរភាពនៃការផ្គត់ផ្គង់ប្រេងឥន្ធនៈនៅកម្ពុជា។

**ប្រការ៥ ._**

គ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ ត្រូវមានប្រភេទផលិតផលប្រេងសាំងធម្មតា និងប្រភេទផលិតផលប្រេងម៉ាស៊ូតលក់ក្នុងតម្លៃមិនលើសពីថ្លៃដែលបានកំណត់ដូចប្រការ៤ នៃប្រកាសអន្តរក្រសួងនេះ។

គ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ ត្រូវមានយ៉ាងតិចនូវប្រភេទផលិតផលប្រេងសាំងធម្មតា (EA92) និងប្រភេទផលិតផលប្រេងម៉ាស៊ូតសម្រាប់លក់ជាប្រចាំ ហើយមិនអនុញ្ញាតឱ្យលក់តែប្រេងសាំងស៊ុបពែរតែមួយមុខ ដោយមិនមានលក់ប្រេងម៉ាស៊ូត និងប្រេងសាំងធម្មតា (EA92) បានទេ។

**ប្រការ៦ ._**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៤.០០០.០០០ (បួនលានរៀល) ចំពោះស្ថានីយលក់រាយប្រេងឥន្ធនៈទាំងឡាយណាដែលល្មើសនឹងប្រការ៥ នៃប្រកាសអន្តរក្រសួងនេះ។ ក្នុងករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយនៅតែបន្តប្រព្រឹត្តបទល្មើសដដែល ស្ថានីយលក់រាយប្រេងឥន្ធនៈនោះ អាចនឹងរងនូវការឱ្យបិទផ្អាកប្រតិបត្តិការជាបណ្តោះអាសន្ន។

**ប្រការ៧ ._**

ការត្រួតពិនិត្យ និងការផាកពិន័យ កំណត់ក្នុងប្រការ៦ ខាងលើ ត្រូវអនុវត្តដោយមន្ត្រីនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំរបស់ក្រសួងពាណិជ្ជកម្ម ដោយសហការជាមួយមន្ត្រីជំនាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល។

**ប្រការ៨ ._**

រាល់ចំណាយលើការទិញព័ត៌មាន MOPS ដែលលក់ដោយក្រុមហ៊ុននៅប្រទេសសិង្ហបុរី ជាបន្ទុករបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ៩ ._**

ក្រសួងពាណិជ្ជកម្ម ត្រូវនាំមុខក្រសួងពាក់ព័ន្ធរៀបចំប្រជុំរៀងរាល់ ០៦ខែម្តង ជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដើម្បីពិនិត្យឡើងវិញអំពីតម្លៃ PREMIUM របស់ស្ថានីយលក់រាយប្រេងឥន្ធនៈនៅកម្ពុជា។

**ប្រការ១០ ._**

ប្រកាសអន្តរក្រសួងនេះ មិនគ្របដណ្តប់ទៅលើការងាររបស់សមត្ថកិច្ច ដែលកំពុងអនុវត្តកាតព្វកិច្ចយកពន្ធទេ។

**ប្រការ១១ ._**

ប្រកាសអន្តរក្រសួងលេខ១៧២ ពណ.អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ត្រូវទុកជានិរាករណ៍។

Kt

**ប្រការ១២ _**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៥រោច ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០២២

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** | **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល** |
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **ប៉ាន សូរស័ក្តិ** | **ស៊ុយ សែម** |

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ